# កម្ពុជសុរិយា

ទស្សនាវដ្តី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ

បោះពុម្ពផ្សាយអំពីពុទ្ធសាសនបណ្ឌិត្យ

ផ្នែកសាសនា បញ្ជីរឿង ទំព័រ


ពុទ្ធសាសនានិងគ្រីស្តសាសនា (សន្និសីទ លោកវេជ្ជបណ្ឌិតមីតូត) (តមក) . . . លោក ភិយ - ប៊ុក . . . . . . . ២៤៤

ពន្លឺអាស៊ីទ្វីប (តមក) . . . . . . . . . លោក ភិយ - ប៊ុក . . . . . . ២៤៩

សង្គហធម៌ . . . . . . . . . . . . . ព្រះវិន័យធម្ម យូរ - ប៊ុណ . . . . ២៥៦


ផ្នែកអក្សរសាស្ត្រ


សារលិខិតនៃលោកស្វាមីវិវេកានន្ទ . . . . . លោក ភិយ - ប៊ុក . . . . . . . ២៦៦

ការបណ្ដុះនិស្ស័យ (តមក) . . . . . . . ព្រះមហាឧត្តមវិជ្ជា ប៊ុត - ប៉ម . . ២៧២

សាវតារវត្តកែវនគរឆ្វៀហៅវកា . . . . . ព្រះមហា តុយ - ហួត . . . . . ២៨០

បញ្ហាភាសិតដប់ពីរ . . . . . . . . . . . លោក ប៊ូ - ក៏ . . . . . . . . . ២៨៣

រឿងសាមកុក (តមក) . . . . . . . . . . — ទួ - កន . . . . . . . . . ២៩៦

ព្រះរាជពង្សាវតារប្រទេសកម្ពុជា (តមក) . . — ឈឹម - ក្រសេម . . . . . ៣០៦


កំណត់ទិនប្បវត្តិការណ៍


ពិធីបុណ្យប្រគេនព្រហ្មទានចំពោះព្រះសង្ឃ ៨៨ រូប ដែលប្រឡងជាប់សញ្ញាប័ត្រ សាលាបាលី ជាន់ខ្ពស់ . . . . . . . . . . . . សមាគមមិត្តសាលាបាលី . . . . ៣១០



មួយឆ្នាំមាន ១២ សៀវភៅ តំឡៃជាវ . . . . . . . . . . . . . ១៤៥ៀ,០០

H
Reçu le 14-6-51
INDOCHINE FRANÇAISE
RÉGIE DU DÉPÔT LÉGAL

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ

INSTITUT BOUDDHIQUE

ឆ្នាំទី ២៣ ខែមេសា លេខ ៤

ព. ស. ២៤៩៣ — គ. ស. ១៩៥១

## សង្គហធម៌

# ព្រះវិន័យធម្ម យូរ-ប៉ុណ្ណ

ក្រុមជំនុំព្រះត្រ័យបិដកនៅពុទ្ធសាសនបណ្ឌិត្យ

**ទេសនាដាក់វិទ្យុឃោសនសព្ទនៃប្រទេសកម្ពុជា កាលពីថ្ងៃ ៨ កើតខែភទ្របទ**

**ឆ្នាំកុរនព្វស័ក ព. ស. ២៤៩០**

---

នមោ តស្ស ភគវតោ សម្មាសម្ពុទ្ធស្ស ។

វេលានេះ អាត្មាភាពនឹងសំដែងអំពីសង្គហធម៌ ដែលជាធម៌សម្រាប់សង្គ្រោះដល់គ្នានឹងគ្នា ដូចតទៅនេះ :-

កិច្ចឬឧបាយដែលសម្រាប់សង្គ្រោះ ឬស្រោចស្រង់គ្នានឹងគ្នាឲ្យបានមូលមិត្រ ហៅថា សង្គហៈ ៗ នេះចែកចេញជា ៤ យ៉ាង គឺ :

១- ទានៈ= ការចែករំលែកឲ្យ,

២- បេយ្យវជ្ជៈ= ការពោលពាក្យពីរោះគួរឲ្យជាប់ចិត្ត,

៣- អត្ថចរិយា = ការប្រព្រឹត្តិឲ្យជាប្រយោជន៍ដល់គ្នានឹងគ្នា,

៤- សមានត្តតា = ភាពជាអ្នកតាំងខ្លួនឲ្យស្មោះចំពោះបុគ្គលផងគ្នា ។

សង្គហធម៌ទាំង ៤ នេះ តែងប្រមូលជនទាំងឡាយឲ្យមូលមិត្រគ្នាក្នុងសកលលោក ៗ បើសង្គហធម៌នេះមិនមានហើយ សាមគ្គី គឺការព្រមព្រៀងមូលមិត្រគ្នា ក៏នឹងផ្ទុះធ្លាយបែកបាក់ទៅពុំខាន ៗ ព្រះពុទ្ធជាម្ចាស់ទ្រង់សរសើរសង្គហធម៌នេះ ថាជាកិច្ចយ៉ាងប្រសើរបំផុតក្នុងលោក ៗ

ឯការសង្គ្រោះនេះ ជាប្រវេណីរបស់បុគ្គលអ្នកស្ថិតនៅក្នុងវ័យជាបុព្វ-ការី ដូចមាតាបិតាមានការៈខាងសង្គ្រោះបុត្តទាសកម្មករ; ឥស្សរជន មានព្រះរាជាជាដើម មានការៈខាងសង្គ្រោះដល់ប្រជារាស្ត្រ ។

ជនដែលបានធ្វើសេចក្តីសង្គ្រោះចំពោះរូបណាមួយហើយ ជននោះ ឈ្មោះថាជាបុព្វការី, ជនជាបុព្វការីនោះ ក៏គួរទទួលយកកិច្ចដែលគេត្រូវធ្វើមកវិញ ។ សូម្បីតែជនអ្នកតូចមិនគិតប្រយោជន៍ផ្ទាល់ខ្លួន ហើយ មានចិត្តមេត្តាសង្គ្រោះដល់ញាតិឯទៀតៗ ក៏គង់មានអ្នកដទៃគេរាប់អាន ជួយលើកតំកើងឲ្យទៅកាន់ទីជាធំបាន ។ ព្រោះហេតុនោះបានជាព្រះពុទ្ធជាម្ចាស់ ទ្រង់មានបំណងនឹងនាំសត្វឲ្យបានសំរេចគុណសម្បត្តិ គឺ ការតាំងខ្លួនត្រូវក្នុងធម៌ ទើបទ្រង់សំដែងនូវសង្គហៈឧបាយនេះទុកជាផ្លូវ ដូចន័យដែលបានពោលមកខាងដើម ។ សង្គហៈនោះ រួមចូលដោយសង្ខេបជា ៤ គឺ: ទានៈ, បេយ្យវជ្ជៈ, អត្ថចរិយា, សមានត្តតា ដូច្នេះ ។

ទានៈ= ការឲ្យ នោះ ចែកចេញជា ២ យ៉ាង គឺឲ្យសំដៅចំពោះរូបបុគ្គលម្នាក់ៗ ហៅថា, អសាធារណទាន ១, ឲ្យជាសាធារណ៍ទូទៅ មិនសំដៅចំពោះរូបបុគ្គលម្នាក់ៗ ហៅថា សាធារណទាន ១ ។ មាតាបិតាឲ្យអាហារគ្រឿងប្រដាប់ស្លៀកពាក់ ដល់បុត្តធីតាក្នុងវេលាដែលនៅកំឡោះក្រមុំ ឬឲ្យទ្រព្យសម្បត្តិធ្វើជាដើមទុន ឲ្យទីឋានផ្ទះសំបែងក្នុងកាលដែលបុត្រធីតាចំរើនវ័យហើយ; ចៅហ្វាយនាយឲ្យគោតសម្បូទ

ដល់ទាសកម្មករ; ញាតិមិត្រចែកចាយគ្រឿងប្រើប្រាស់ទឹកភោជនាហារ ដល់គ្នីគ្នា ៗ បុត្រធីតាដែលមានផ្ទះសម្បែងហើយ បានជូនភោជនាហារគ្រឿងស្លៀកពាក់ដល់មាតាបិតាដែលចាស់ជរា, ទាសកម្មករធ្វើការងារប្ដូនរបស់ដល់ចៅហ្វាយនាយជាហេតុសំដែងសេចក្ដីចងមេត្រីទៅរកចៅហ្វាយនាយ; យ៉ាងនេះហៅថា អសាធារណទាន គឺបូជាឧបការគុណចំពោះរូបបុគ្គលម្នាក់ៗ ៗ

ឥស្សរជន ឬអ្នកមានទ្រព្យសម្បត្តិ ជាអ្នកមានចិត្តផ្សាយមេត្តាករុណាគិតអាសូរប្រណីដល់មហាជន ហើយលះបង់សេចក្ដីកំណាញ់បរិច្ចាគទ្រព្យជួលគេឲ្យលើកថ្នល់ ជីកព្រែក ធ្វើស្ពាន ដើម្បីជាផ្លូវគមនាគមន៍បានស្រួល, សង់សាលា ដាំដើមឈើ ជីកស្រះ ដើម្បីជាទីសំណាក់អាស្រ័យដល់មនុស្សអាគន្តុកៈ, តាំងបង្កើតឬទំនុកបម្រុងធ្វើផ្ទះពេទ្យជាទីព្យាបាលរោគសព្វយ៉ាង, តាំងបង្កើតឬទំនុកបម្រុងសាលាបង្រៀនជាទីឲ្យចំណេះវិជ្ជាដល់កុមារកុមារី ៗ យ៉ាងនេះហៅថាឲ្យឬសង្គ្រោះជាសាធារណៈមិនចំពោះរូបបុគ្គល ៗ ទានមានសភាពយ៉ាងនេះ អាចឲ្យសេចក្ដីសុខដ៏ធំទូលាយ ជាងឲ្យចំពោះរូបបុគ្គលម្នាក់ៗ ព្រោះពង្រីកមេត្តាចិត្តផ្សាយទៅក្នុងលោកទាំងមូល ៗ ការឲ្យដោយសេចក្ដីសង្គ្រោះឬដោយសេចក្ដីផ្សាយមេត្តាចិត្តយ៉ាងនេះ ចាត់ជាបារមី ១ ហៅថា ទានបារមី ៗ ទានបារមីនេះព្រះពុទ្ធជាម្ចាស់ ធ្លាប់បានបំពេញបានសន្សំមកច្រើនជាតិ

ត់គគណនាឡើយ, លុះព្រះអង្គបានត្រាស់ហើយទ្រង់សំដែងនូវសង្គហ-ធាននេះថាជាកន្លែងបង្កំណើតនៃសេចក្ដីសុខក្នុងលោកនេះ និងលោកខាងមុខ ។ ធាននេះជាសង្គហៈទី ១ ។

អ្នកឲ្យទាន បើត្រានតែឲ្យប៉ុណ្ណោះមិនបានពោលពាក្យពីរោះគួរឲ្យចាប់ចិត្តផងទេ, វត្ថុដែលឲ្យនោះ បើទុកជាច្រើនយ៉ាងណាក៏ដោយចុះ ក៏ប្រាកដហាក់ដូចជាតិច, បើពោលពាក្យពីរោះគួរឲ្យស្រណោះចាប់ចិត្ត ក៏វត្ថុការដែលឲ្យនោះសូម្បីតិចតួចសោះ ក៏ប្រាកដហាក់ដូចជាច្រើន ព្រោះធ្វើឲ្យកើតសេចក្ដីស្រឡាញ់ពេញចិត្ត ធ្វើអ្នកដែលមានឧបការៈឲ្យជាទីរាប់អានក្រៃលែងឡើង ។ ព្រោះហេតុនោះ បានជាព្រះសម្ពុទ្ធជាម្ចាស់ទ្រង់ចាត់បេយ្យវជ្ជៈ ថាជាសង្គហៈទី ២ ។

**បេយ្យវជ្ជៈ** ប្រែថា "ពាក្យដែលពីរោះគួរពេញចិត្តគួរចាប់ចិត្ត" ចែកចេញជា ២ យ៉ាង គឺ **បិយវាចា** = បានខាងវាចាពីរោះទន់ផ្អែមធ្វើអ្នកនិយាយឲ្យជាទីស្រឡាញ់របស់អ្នកស្ដាប់ ១, **អត្ថសញ្ហិតា វាចា** = វាចាប្រកបដោយប្រយោជន៍ ១ ។

បិយវាចា អាចនឹងទាញចិត្តមនុស្សក្នុងលោកឲ្យស្រឡាញ់រាប់រកគ្នាបាន ដូចមាតាបិតាចរចានឹងបុត្រធីតាដោយពាក្យទន់ផ្អែម, ដូចហៅថា កូន ថា នាង ដូច្នេះជាដើម ពាក្យនេះគួរឲ្យចាប់ចិត្តដល់បុត្រធីតាពន់ពេក ធ្វើឲ្យកើតសេចក្ដីស្រឡាញ់ ។ បុត្រធីតាដែលចេះនិយាយពាក្យពីរោះ

គួរឲ្យចាប់ចិត្ត, មាតាបិតាក៏ស្រឡាញ់ពេញចិត្ត ៗ ជនជាឥស្សរៈដែលឈ្លាសក្នុងការបដិសន្ថារៈ ពោលពាក្យកក់ទាក់ប្រស្រ័យរួសរាយដល់អ្នកតូចធំទៅគ្រប់ជាន់គ្រប់ថ្នាក់ រមែងធ្វើខ្លួនឲ្យជាទីស្រឡាញ់ពេញចិត្តរបស់មនុស្សទាំងឡាយ ចេះនិយាយដឹកនាំអ្នកតូចឲ្យមានគំនិតធ្វើកិច្ចការដោយសេចក្ដីប្រឹងប្រែងហើយឲ្យសុចរិតបានផង ៗ វាចាទន់ភ្លន់នេះឯង · បើទុកជាមនុស្សនោះពីដើមមកធ្លាប់ទាស់ទែងនឹងខ្វែងគំនិតគ្នា ដល់ទៅមើលមុខគ្នាមិនត្រង់ក៏ដោយ កាលបើបានឮសំដីពីរោះញយៗ ក៏អាចនឹងស្រាយកំហឹងនោះបាន ៗ ដូចពាក្យបុរាណលោកពោលថា "សំដីជាឯក លេខជាទោ" សំដីនេះលើកទុកជាទីមួយ ចំណេះវិជ្ជាទុកជាទីពីរ ៗ អ្នកដែលមានចំណេះយ៉ាងណាក៏ដោយចុះ, ប៉ុន្តែបើពោលវាចាមិនជាទីគាប់ចិត្ត ជាវាចាគំរោះគំរើយមិនពេញចិត្តអ្នកស្ដាប់, អ្នកមានចំណេះក៏ទៅជាឥតមានគេរាប់រកទៅវិញ ៗ ជនអ្នកខ្សត់ខ្សោយចំណេះវិជ្ជាសោះទេ ប៉ុន្តែបើមានវាចាពីរោះ ចេះទន់ទោនសុភាពរាបសាល្អគួរឲ្យពេញចិត្ត. គង់មានអ្នកដទៃគេរាប់រកគេជួយសង្គ្រោះគេបូជា ឬឲ្យរត្ននេះនោះពុំខាន ៗ ទាំងនេះក៏ដោយសារតែវាចាពីរោះ ៗ ប៉ុន្តែមនុស្សម្នាក់ៗ មិនត្រូវធ្វើខ្លួនឲ្យឥតចំណេះវិជ្ជាទេ. ត្រូវតែខំប្រឹងរៀនសូត្រវិជ្ជាផ្លូវលោកផ្លូវធម៌ជាដរាប ៗ

អត្តសញ្ញាត វាចា = វាចាប្រកបដោយប្រយោជន៍នោះ សេចក្ដីថាជនអ្នកស្រឡាញ់សេចក្ដីសុខ - ចំរើន និយាយតែសំដីណាដែលប្រកប

ដោយប្រយោជន៍ ជាសំដីមានតម្លៃឲ្យអ្នកស្តាប់ចូលចិត្តចង់ស្តាប់, ហើយអ្នកស្តាប់នោះយកទៅធ្វើតាមប្រតិបត្តិតាមទៅ ក៏រមែងកើតផលកើតប្រយោជន៍ ៗ សំដីយ៉ាងនេះ ចាត់ជាសំដីបានការ ជាសំដីអ្នកប្រាជ្ញ ។

ព្រះបរមសាស្តា ទ្រង់ទេសនាដឹកនាំវេនេយ្យសត្វ ឲ្យឃើញដោយបញ្ញាថា យ៉ាងនេះជាធម៌ យ៉ាងនេះមិនមែនជាធម៌. ទ្រង់ពន្យល់ឲ្យលះអកុសលធម៌ចេញ ហើយឲ្យសមាទានយកកុសលធម៌វិញ ឲ្យអាចហានរើកយកនូវកុសលធម៌នោះៗ ទ្រង់បណ្តុះសេចក្តីក្លាហានរបស់មហាជនទាំងគ្រហស្ថទាំងបព្វជិតឲ្យមានកម្លាំងតាំងនៅអស់កាលដ៏យូរអង្វែង ៗ ព្រះពុទ្ធសាសនា ដែលនឹងអាចតាំងនៅបានរហូតមកដល់សព្វថ្ងៃនេះ ក៏អាស្រ័យព្រះពុទ្ធវាចា ជាវាចាពិត ជាវាចាមានប្រយោជន៍ ៗ វាចាមានប្រយោជន៍នេះ ជាសំដីកាត់ថ្លៃពុំបាន ។ ការពោលពាក្យពីរោះយ៉ាងនេះចាត់ជាសង្គហៈទី ២ ។

**អត្ថចរិយា** គឺការប្រព្រឹត្តិជាប្រយោជន៍ដល់គ្នានោះ អធិប្បាយថា បើប្រសិនជាឲ្យ ឬនិយាយពាក្យពីរោះ ជាគុណតាមចិត្តចងមេត្រីទុកបានយ៉ាងស្និទ្ធក៏ពិត, ប៉ុន្តែបើជាមនុស្សចេះតែមើលបំណាំគ្នាទៅវិញទៅមក មិនប្រព្រឹត្តប្រយោជន៍ដល់គ្នានឹងគ្នា គឺថាមិនហុចប្រយោជន៍ឲ្យ មិនប្រាប់ឧបាយឲ្យកើតប្រយោជន៍ឲ្យ គ្រាន់តែឲ្យរបស់ប្រើប្រាស់ និងនិយាយតាមការសម្រួលប៉ុណ្ណោះ ការជិតស្និទ្ធនោះ ក៏នឹងសាបរលាបទៅ

វិញបានដោយងាយ ៗ ព្រោះហេតុនោះ អត្ថចរិយា ការប្រព្រឹត្តជាប្រយោជន៍ដល់គ្នានិងគ្នានេះ ក៏ជាគុណយ៉ាងសំខាន់អាចយឹតយោងគ្នាឲ្យទៅកាន់សេចក្ដីសុខ – ចំរើនតរៀងទៅបាន ៗ

ឯការយឹតយោងឲ្យប្រយោជន៍ដល់គ្នានិងគ្នានោះ ដូចជាមាតាបិតាខ្វល់ខ្វាយធ្វើប្រយោជន៍ឲ្យបុត្រធីតា គឺខំស្វែងរកទ្រព្យសម្បត្តិ ចំណេះវិជ្ជាផ្ដល់ឲ្យបុត្រធីតាតាមឋានតាមថ្នាក់; ចំណែកបុត្រធីតាវិញ ក៏ជួយខ្វល់ខ្វាយក្នុងកិច្ចការរបស់មាតាបិតា គឺជាត្រូវចិញ្ចឹមលោកដោយការតបគុណ ៗ ឥស្សរជនជួយធុរៈដល់អ្នកដែលត្រូវការពឹងពាក់ព្យាបាលទំនុកបំរុងឲ្យមានកេរ្តិ៍ឈ្មោះយសស័ក្តិប្រាកដក្នុងទីប្រជុំជន, រមែងជាទីនិយមរាប់អានរបស់អ្នកពឹងពាក់, អ្នកដែលពឹងពាក់ទៀតសោត ក៏ត្រូវធ្វើកិច្ចការរបស់លោកឲ្យសម្រេចតាមទំនងដែលលោកប៉ុនប៉ង, ធ្វើខ្លួនឲ្យលោកជឿជាក់និងទុកចិត្តបាន ឲ្យលោកស្រឡាញ់រឹងរឹតតែខ្លាំងឡើង ៗ

មិត្រសំឡាញ់ ក៏ត្រូវជួយខ្វល់ខ្វាយកិច្ចធុរៈគ្នាទៅវិញទៅមកដោយកម្លាំងកាយខ្លះ ដោយកម្លាំងវាចាខ្លះ កម្លាំងគំនិតខ្លះ កម្លាំងទ្រព្យខ្លះ ឲ្យសមតាមទំនងពុទ្ធភាសិតថា អត្ថម្ហិ ជាតម្ហិ សុខា សហាយា "មិត្រសំឡាញ់ទាំងឡាយ, កាលបើធុរៈកើតឡើង, រមែងជួយនាំឲ្យបានសេចក្ដីសុខ" ទើបមានមេត្រីចិត្តរាប់អានគ្នាយ៉ាងស្និទ្ធ ៗ សូម្បីញាតិក៏ដូចគ្នា ត្រូវតែជួយធុរៈគ្នា តាមលំដាប់ញាតិ, មិនចាំបាច់ញាតិសាច់សាលោហិត

ជិតគ្នាទេ ឲ្យតែរួមជាតិជាមួយគ្នា ក៏ត្រូវតែជួយផ្តល់ប្រយោជន៍ឲ្យតាមសមគួរ, យ៉ាងនេះទើបរាប់រកគ្នាទៅពេលមុខបានស្រួលល្អ ។ ឯការដឹកនាំក្នុងផ្លូវធម៌ទៀតសោត ក៏ត្រូវបបួលគ្នាឲ្យបរិច្ចាគធនធានធ្វើកុសល ដើម្បីនឹងញុំាងគ្នាឲ្យស្រុះស្រួលគំនិតក្នុងការបុណ្យនោះ ឲ្យចេះស្និទ្ធស្នាលគ្នាតទៅ ។ ដូចជនអ្នកមានសីលធម៌ល្អអាចដឹកនាំអ្នកឥតសទ្ធាឲ្យមានសទ្ធា, ឥតសីលឲ្យមានសីល, កំណាញ់ស្វិតស្វាញឲ្យមានចិត្តទូលាយបរិច្ចាគទ្រព្យធ្វើបុណ្យ, អ្នកល្ងង់ខ្លៅ ឲ្យមានប្រាជ្ញា ។ យ៉ាងនេះឈ្មោះថាប្រព្រឹត្តប្រយោជន៍ដល់គ្នានឹងគ្នា រាប់ថាជាសង្គហៈទី ៣ ។

**សមានតតា** ភាពជាអ្នកតាំងខ្លួនឲ្យស្មោះស្មើទៅរកបុគ្គលផងគ្នា នោះអធិប្បាយៈ បុគ្គលសូម្បីត្រាន់តែឲ្យ ប្តូនិយាយពាក្យពីរោះព្រម តាំងជួយខ្វល់ខ្វាយធ្វើប្រយោជន៍ ឬណែនាំប្រាប់ប្រយោជន៍ដល់គ្នានឹងគ្នាតែប៉ុណ្ណោះ, តែបើមិនចេះរៀបចំខ្លួនប្រាណឲ្យសមតាមអត្តភាព គឺមិនស្គាល់ធំ-តូច-ខ្ពស់-ទាប ជាអ្នកប្រកាន់មានះក្អេងក្អាង មើលងាយគេធ្វើឫកពាក្រអឺតក្រអោងយ៉ាងនេះទេ, សេចក្តីរាប់អានគ្នា ក៏នឹងសាបរលាបទៅវិញ ។ លុះតែអាស្រ័យនូវសេចក្តីស្មោះស្មើ ឲ្យសមតាមអត្តភាពខ្លួនផង ទើបសេចក្តីរាប់អាននោះនឹងមានកម្លាំងអាចតាំងនៅយូរអង្វែងទៅបាន ។

ជនអ្នកមានវ័យតិច សូម្បីវិសេសជាងដោយយសសក្តិ ដោយអំណាច ដោយភោគសម្បទ ដោយបរិវារប៉ុណ្ណា ក៏ត្រូវតាំងខ្លួនឲ្យសមតាមបែប

ភាពយសសក្តិជាដើមប៉ុណ្ណោះ គឺត្រូវតែតំទាប់គាប់គួរដល់ជនអ្នកមានវ័យចំរើនជាងខ្លួន, ពីដើមមកធ្លាប់គប់ការនយ៉ាងណា ខាងក្រោយមកក៏ត្រូវគប់ការនយ៉ាងនោះ ៗ ជនទាំងឡាយដែលបានទទួលសេចក្តីគោរពកោតក្រែងយ៉ាងនេះហើយ ក៏រមែងស្រឡាញ់ពេញចិត្ត សំដែងការការគប់រកទៅវិញ ៗ

ពួកញាតិដែលមានវ័យស្មើៗ គ្នាទៀតសោត ក៏ត្រូវសំដែងសេចក្តីគប់ការនគ្នាដោយពេញចិត្តចំពោះញាតិផងគ្នា, ទោះនិយាយស្តីក្តី ធ្វើការងារអ្វីក្តី ដេក ដើរ ឈរ អង្គុយក្តី ក៏ត្រូវប្រព្រឹត្ត ត្រូវធ្វើ ត្រូវនិយាយស្តីឲ្យសមតាមអត្តភាពរបស់ខ្លួន ៗ ញាតិដែលជាអ្នកធំមានមេត្តាគប់ការនញាតិដែលជាអ្នកតូច ស្និទ្ធស្នាលគ្នាទៅវិញទៅមក ជួយគ្នាទៅវិញទៅមក ដើម្បីគាំពារវង្សត្រកូលរបស់ខ្លួនឲ្យចំរើន; សេចក្តីសាមគ្គីនៃញាតិនេះ រមែងញុំាងសេចក្តីសុខឲ្យកើតមានទូទៅសព្វគ្នា; ដូចមានពុទ្ធភាសិតថា ធីរោ ច សុខសំវាសោ ញាតីនំវ ស-មាគមោ "អ្នកប្រាជ្ញដែលមានមនុស្សមកនៅរួមជាមួយហើយ រមែងញុំាងសុខឲ្យកើត ដូចជាការជួបជុំនៃពួកញាតិដូច្នោះដែរ" ៗ

មួយទៀតជនដែលអាស្រ័យនៅក្នុងគណៈ ដូចជាភិក្ខុសង្ឃដែលអាស្រ័យនៅជាមួយគ្នាបាន ក៏ដោយអំណាចមានធម៌ស្មើគ្នា ៗ បើមិនដូច្នោះទេ ក៏មិនអាចនឹងរក្សាសាមគ្គីឲ្យគង់នៅបានឡើយ ៗ ព្រោះ

ហេតុនោះ បានជាលោកដែលជាប្រធាននៃគណៈ ត្រូវបំភ្លឺដើម្បីឲ្យមនុស្សទាំងឡាយក្នុងគណៈ និយមធ្វើតាមសណ្តាប់ធ្នាប់របស់គណៈ កំចាត់បង់នូវមនុស្សដែលល្មើសចេញ ហើយរក្សាសាមគ្គីរបស់គណៈឲ្យតាំងនៅមាំមួនទៀង ។

សមានត្តតានេះ បើធ្វើឲ្យសមដល់ហេតុផលរបស់បុគ្គល ឬគណៈ ហើយ រមែងយឹតយោងបុគ្គលនឹងគណៈនោះ ឲ្យតាំងនៅក្នុងសាមគ្គីធម៌យ៉ាងជិតស្និទ្ធបាន ។ នេះចាត់ជាសង្គហទ័ ៤ ។ សំដែងមកក្នុងសង្គហធម៌ទាំង ៤ ចប់តែប៉ុណ្ណេះ ។

កាលបើចប់ធម្មទេសនាហើយ សូមផ្សាយចំណែកកុសល ដល់អស់លោក-អ្នកទាំងឡាយ ដែលស្ថិតនៅក្នុងកម្ពុជរដ្ឋទាំងមូល សូមឲ្យបានសេចក្តីសុខចំរើនតរៀងទៅ ! ។

ទុក្ខប្បត្តា ច និទ្ទុក្ខា ភយប្បត្តា ច និព្ភយា
សោកប្បត្តា ច និស្សោកា ហោន្តុ សព្វេបិ បាណិនោ ។

សព្វសត្វទាំងឡាយដែលដល់ហើយនូវសេចក្តីទុក្ខ ក៏ឲ្យបាត់ទុក្ខទៅ ! ដែលដល់នូវភ័យ ក៏ឲ្យបាត់ភ័យទៅ ! ដែលដល់នូវសេចក្តីសោក ក៏ឲ្យបាត់សោកទៅ ! (ដោយអំណាចធម្មទេសនានេះ) ។